មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍
សើស្បែក និងកាមរោគ

# សិក្ខាសាលាថ្នាក់តំបន់ ស្តីពី«ការពិនិត្យមើលលទ្ធផល និងការពង្រឹងគុណភាពជាបន្ត ក្នុងការស្វែងរកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥.៩៥.៩៥»



មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំវគ្គសិក្ខាសាលាថ្នាក់តំបន់ ស្តីពី « ការពិនិត្យមើលលទ្ធផល និងការពង្រឹងគុណភាពជាបន្ត ក្នុងការស្វែងរកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥.៩៥.៩៥ » ដែលប្រព្រឹត្តទៅនាថ្ងៃទី១២ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៥ នៅមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តតាកែវ ដោយមានការគាំទ្រថវិកា និងបច្ចេកទេស ដោយគម្រោង US-CDC Cambodia ។ គោលបំណង នៃសិក្ខាសាលានេះ គឺដើម្បីជាជា នូវ លទ្ធផល និងសមមាត្រខ្ពស់ នៃល្បាក់ទាំងមូលតាំងពីការរកឃើញអ្នកផ្ទុកមេរោគអេដស៍ រហូតដល់ចុះឈ្មោះ ទទួលសេវាថែទាំ និងព្យាបាលប្រកបដោយគុណភាព។ សិក្ខាសាលានេះក្រោមអធិបតី **លោកសាស្ត្រាចារ្យ ជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ អេដស៍ សើស្បែក និងកាមរោគ **លោកឱសថការី ផាន់ វ៉ាន់** ប្រធានមន្ទីរ សុខាភិបាល នៃរដ្ឋបាល ខេត្តតាកែវ និង **លោកវេជ្ជ. លី វណ្ណាធី** អនុប្រធានមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺមិនឆ្លងសហរដ្ឋអាមេរិកអ្នកជំនាញសុខភាពសាធារណៈ ដែលបានផ្តល់មតិ



សំណេះសំណាល ក្នុងនោះលោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា បានចូលរួមជាមតិយោបល់ព្រមទាំងប្រកាសបើកអង្គសិក្ខាសាលា។



សិក្ខាសាលានេះមានការចូលរួមពីផ្នែកជំនាញរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដូចជា ផ្នែក AIDS Care ផ្នែក BCC ផ្នែក STI ផ្នែក Laboratory ផ្នែក DMU ផ្នែក VCCT ផ្នែក Technical Bureau គ្លីនិក NCHADS ART និងមានការចូលរួមពីប្រធានកម្មវិធីអេដស៍ខេត្ត ប្រធានក្រុម ART មកពីតាមបណ្តាខេត្តជាជា និងអង្គការដៃគូ ដូចជា PC AHF សរុបចំនួន ៩៦ នាក់។ សិក្ខាសាលាមានការធ្វើបទបង្ហាញពីលទ្ធផលដែលសម្រេចបានទៅតាមសូចនាករ សំខាន់ៗទាក់ទង នឹង៩៥ទី១៖ ចំនួនអ្នកមានតេស្តប្រតិកម្មរកឃើញថ្មី ភាគរយអ្នកបញ្ជាក់ថាវិជ្ជមាន HIV បានចុះឈ្មោះនៅសេវា ART ចំនួន HIVST បានធ្វើតេស្តបញ្ជាក់ មានលទ្ធផលតេស្តបញ្ជាក់វិជ្ជមាន HIV និងលទ្ធផលសម្រេចបាននៃសូចនាករសំខាន់ៗទាក់ទងនឹង ៩៥ទី២ និង៩៥ទី៣៖ ភាគរយអ្នកជំងឺ ART ដែលបានស្លាប់ អ្នកជំងឺខកណាត់ និងបាត់មុខដែលបានដាក់អោយទទួល សេវាវិញ ការពិនិត្យតាមការណាត់មុនថ្ងៃណាត់ យឺតនៅថ្នាំបម្រុង យឺតអស់ថ្នាំបម្រុង និងកំណត់បញ្ហាអាទិភាព មូលហេតុដែលទាក់ទងនឹងលទ្ធផលនៃសូចនាករទាប និងរៀបចំផែនការសកម្មភាពដើម្បីកែលម្អរនៅ។



